**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ : ២១៩ មស. សជណ

ថ្ងៃ សុក្រ ៩កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០២១

# សេចក្ដីជូនដំណឹង

**យោង** ៖- ប្រកាសលេខ៣៩១៧ មស.ក្រខ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ
- សេចក្ដីជូនដំណឹងលេខ៩៧៨មស.សជណ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ
- សេចក្ដីជូនដំណឹងលេខ១៨៩មស.សជណ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ របស់ក្រសួងមុខងារសាធារណៈ
- លិខិតលេខ០០៨០ រលអស ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

យោងតាមសំណូមពរការងារចាំបាច់ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល គណៈកម្មការរៀបចំការប្រឡងសូមជម្រាបជូនដំណឹងដល់បេក្ខជន និស្សិត និងមន្ត្រីរាជការទាំងអស់ ឱ្យបានជ្រាបថា៖ គណៈកម្មការរៀបចំការប្រឡងសូមធ្វើការកែសម្រួលលើទំព័រទី៧ នៃសេចក្ដីជូនដំណឹងលេខ១៨៩ មស.សជណ ដូចមានយោងខាងលើត្រង់ចំណុចទី៦ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល លេខរៀងទី៦ នាយកដ្ឋានលទ្ធភាពហោះហើរ ជ្រើសរើសក្របខ័ណ្ឌប្រភេទ **ក** ចំនួន **០៣កន្លែង** ទៅជាជ្រើសរើសក្របខ័ណ្ឌប្រភេទ **ក** ចំនួន **០២កន្លែង** និងជ្រើសរើសក្របខ័ណ្ឌប្រភេទ **គ** ចំនួន **០១កន្លែង** វិញដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | អង្គភាព | ចំនួនជ្រើសរើស | ប្រភេទក្របខ័ណ្ឌ |
|---|---|---|---|
| ៦ | នាយកដ្ឋានលទ្ធភាពហោះហើរ | ០២ | ក |
| | | ០១ | គ |

១. លក្ខខណ្ឌនៃការជ្រើសរើស បេក្ខជនប្រឡងជ្រើសរើសក្របខ័ណ្ឌប្រភេទ **គ** ត្រូវមានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្រសមមូល និងមានអាយុមិនលើសពី **២៥ឆ្នាំ**។

២.វិញ្ញាសាប្រឡងសម្រាប់បេក្ខជនប្រឡងជ្រើសរើសប្រភេទក្របខ័ណ្ឌ **គ** ត្រូវបានកំណត់ដូចខាងក្រោម៖
- ម៉ោងទី១ ៖ ចំណេះដឹងទូទៅថ្នាក់ទី១២ រយៈពេល ០១ម៉ោង ៖ ៣០នាទី
- ម៉ោងទី២ ៖ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០១ម៉ោង ៖ ៣០នាទី

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល មេត្តាជ្រាបជាព័ត៌មាន៕

**រដ្ឋលេខាធិការ និងជា**
**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**អែម ប៊ុនថុល**

**ចម្លងជូន៖**
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
"ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ